# ការសម្ភាសន៍របស់អ៊ុំប្រុស ចិន ជឹម

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ចិន ជឹម

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ ចិន ជឹម</u>

អ៊ុំប្រុស ចិន ជឹមគាត់មានអាយុចិត្តសិបឆ្នាំ។
ហើយគាត់មានបងប្អូនប្រាំមួយនាក់តែបានស្លាប់អស់ហើយនៅសល់តែពីរនាក់ប៉ុណ្ណោះ។
ឪពុកម្តាយរបស់គាត់បានលែងលះគ្នា
ហើយម្តាយរបស់គាត់បានយកគាត់មកនៅជាមួយគាត់នៅកោះដាច់។
ហើយម្តាយរបស់គាត់បានស្លាប់នៅពេលត្រឡប់មកពីជំនាន់ពលពតវិញដោយសារជម្ងឺ។
ហើយម្តាយមីងរបស់គាត់បានជួយរៀបចំអោយគាត់មានប្រពន្ធ
ហើយគាត់មានកូនចំនួនបួននាក់ ហើយសព្វថ្ងៃនេះគាត់មានចៅចំនួន៦នាក់ ហើយ។
ហើយសព្វថ្ងៃនេះគាត់ដើរទិញអេតចាយដើម្បីរកកំរៃមកចិញ្ចឹមជីវិត។ ជីវិតគាត់មានការ
លំបាកតាំងពីគាត់នៅតូចរហូតមកដល់ពេលនេះ
តែគាត់ជាមនុស្សដែលមានការតស៊ូបំផុត។

កៈ ហើយអញ្ចឹង ជាដំបូងសូមជំរាបសួរអ៊ុំប្រុស ខ្ញុំឈ្មោះ គង់ ចាន់ណាក់
ហើយខ្ញុំមកពីគម្រោងជីវ ប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា
ដែលគម្រោងនឹងធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅ សហរដ្ឋអាមេរិច
ឈ្មោះថាសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដោយសារសាកលវិទ្យាល័យមានគោល
បំណងដើម្បីជួយថែរក្សានូវប្រវត្តិរបស់ប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយគាត់អាច រៀន។ ហើយអញ្ចឹង សំរាប់ការសម្ភាសន៍របស់យើងធ្វើឡើងនៅភូមិក្បាលកោះ
ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
ហើយការសម្ភាសន៍នេះយើងធ្វើនៅថ្ងៃទី០២ ខែ០៦ ឆ្នាំ២០១៨។ ជាដំបូងសុំសួរអ៊ុំប្រុស
តើអ៊ុំប្រុសមានឈ្មោះអ្វីដែរ អ៊ុំប្រុស?

ខៈ ខ្ញុំឈ្មោះ ចិន ជឹម។

កៈ ចិន ជឹម! ហើយអញ្ចឹង អ៊ុំប្រុសមានឈ្មោះហៅក្រៅទេ អ៊ុំ?

ខៈ ខ្ញុំអត់មានទេ។

កៈ អត់មានទេអ៊ុំប្រុស! ហើយអញ្ចឹង សំរាប់កាលអ៊ុំនៅក្មេងៗណាអ៊ុំប្រុស អញ្ចឹង អ្នកជិតខាង ឬមួយមិត្តភក្តិអី គាត់ហៅអ៊ុំប្រុសថាម៉េចដែរ កាលនៅក្មេងៗ?

ខៈ គេហៅឈ្មោះខ្ញុំ ចិន ជឹម អញ្ចឹងម៉ង។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើអ៊ុំប្រុសមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំប្រុស?

ខៈ ខ្ញុំមានអាយុចិតសិបឆ្នាំហើយ។

កៈ ហើយអញ្ចឹង តើអ៊ុំប្រុសមាននៅចាំទេថា អ៊ុំប្រុសបានកើតនៅពេលណាទេ?

ខៈ ខ្ញុំអត់បានចាំទេ។

កៈ អូ! អ៊ុំប្រុសអត់ចាំទេ។ អញ្ចឹងអ៊ុំប្រុសអាយុចិតសិបឆ្នាំ អញ្ចឹងអ៊ុំប្រុសប្រហែលជាកើតនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយសែសិបប្រាំបី។ ហើយអញ្ចឹង ចុះសំរាប់ឆ្នាំខ្មែរយើងវិញ តើអ៊ុំប្រុសបានកើតឆ្នាំអីដែរ ឆ្នាំខ្មែរយើងដូចជា ជូត ឆ្លូវ ខាល ថោះ?

ខៈ ខ្ញុំអត់ចាំដែរនឹង។

កៈ ហើយអញ្ចឹង សំរាប់អ៊ុំប្រុស តើអ៊ុំប្រុសបានកើតនៅកន្លែងណាដែរ អ៊ុំប្រុស?

ខៈ ស្រុកកំណើតខ្ញុំពីដើមគេហៅវាលឃ្លាំងមឿង តែបើតាមពិតប្រាកដគេហៅ ស្វាសម្លូរ ភូមិនៅត្រើយម្ខាងតែគេហៅភូមិវាលឃ្លាំងមឿងចឹងទៅ។

កៈ ហើយអញ្ចឹង ភូមិវាលឃ្លាំង តើនៅក្នុងឃុំអ្វីដែរ អ៊ុំប្រុស?

ខៈ កាលពីដើមខ្ញុំនៅតូចៗអត់ដឹងថានៅក្នុងឃុំអីទេ ព្រោះអីវានៅដាច់ស្រយាល។

កៈ ហើយអញ្ចឹង តើឆ្ងាយពីទីនេះទេ អ៊ុំប្រុស?

ខៈ អូ! នៅក្នុងនោះ ឆ្លងទន្លេនឹងទៅ នៅក្នុងទៅទៀត។

កៈ អូ! អញ្ចឹងមានន័យថា យើងឆ្លងទន្លេនឹងទៅ ហើយវានៅក្នុងទៅទៀត។ ហើយអញ្ចឹង តើនៅក្នុងខេត្តកណ្តាលយើងដែរ ឬមួយនៅក្នុងខេត្តណាដែរ អ៊ុំប្រុស?

ខៈ កាលពីដើមនៅនឹងអត់មានដឹងខេត្ត អត់ដែលមានលឺគេហៅ។

កៈ អូ! អញ្ចឹងកាលនោះគេអត់ទាន់មានបែងចែកខេត្តទេអ៊ុំប្រុស។

ខៈ គេមិនទាន់បែងចែកខេត្តទេ។

ក៖ ហើយអញ្ចឹង សំរាប់នៅក្នុងក្រុមគ្រួសារអ៊ុំប្រុស មានបងប្អូនចំនួនប៉ុន្មាននាក់ដែរ អ៊ុំប្រុស?

ខ៖ ខ្ញុំអស់ហើយ អត់មានទេ អូ! នៅបងស្រីមួយនៅពុកឫស្សី នឹងដូចបងបង្កើតដែរ ដោយសារយើងមានម្ដាយដោយខ្លួនតែឪពុកតែមួយ។

ក៖ ហើយអញ្ចឹង បើសិនជាសាច់បង្កើតចឹង តើមានប៉ុន្មាននាក់?

ខ៖ មានតែពីរនាក់គាត់នឹង។

ក៖ ចង់និយាយថាទាំងអស់តែម្ដង អត់រាប់ទាំងអ្នកស្លាប់ទេ?

ខ៖ អត់រាប់ទាំងអ្នកស្លាប់នៅតែពីរនាក់បងស្រីនឹង។

ក៖ ហើយអញ្ចឹង បើសិនជារាប់ទាំងអ្នកស្លាប់ទាំងអស់ តើអ៊ុំប្រុសមានបងប្អូនចំនួនប៉ុន្មាននាក់?

ខ៖ រាប់ទាំងអស់បងប្អូនខ្ញុំមានប្រាំមួយនាក់។

ក៖ អញ្ចឹងមានន័យថាបងប្អូនអ៊ុំប្រុសទាំងអស់មានប្រាំមួយនាក់។ ហើយអញ្ចឹង តើអ៊ុំប្រុសមាននៅចាំឈ្មោះរបស់ពួកគាត់ទាំងប្រាំមួយនាក់ទេ?

ខ៖ ខ្ញុំនៅចាំ បងទីមួយឈ្មោះហួន (ស្រី) ទីពីរឈ្មោះ ជឿន (ប្រុស) ទីបីឈ្មោះ ហឿង ទីបួនឈ្មោះ ច្រឹប ទីប្រាំឈ្មោះ ខ្លឹង ហើយទីប្រាំមួយខ្ញុំនឹង។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំប្រុសជាកូនទីប៉ុន្មានដែរ អ៊ុំជាកូនទីប្រាំមួយតែម្ដង?

ខ៖ បាទ! ខ្ញុំជាកូនទីប្រាំមួយ។

ក៖ អញ្ចឹងមានន័យថាអ៊ុំប្រុសជាកូនពៅគេ។ ហើយអញ្ចឹង សំរាប់អ៊ុំប្រុស តើអ៊ុំប្រុសចាំទេថាកាលពីនៅក្មេងៗ អ៊ុំប្រុសចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ៊ុំទេ?

ខ៖ ខ្ញុំកាលនៅក្មេងៗអត់មានធ្វើអីទេ ខ្ញុំមកគ្រាន់តែនៅជាមួយម្ដាយ ខ្ញុំបែកពីបងប្អូនខ្ញុំនៅតែម្នាក់ខ្ញុំនៅជាមួយម្ដាយ។

ក៖ ហើយអញ្ចឹង បែកគ្នាដោយសារអ្វីដែរ ដោយសារឪពុកម្ដាយបែកគ្នា ឬមួយដោយសារមានមូលហេតុអ្វីដែរ?

ខ៖ ឪពុកម្ដាយរបស់ខ្ញុំគាត់លែងលះគ្នាកាលខ្ញុំនៅតូចនឹងណា ហើយអញ្ចឹងម្ដាយខ្ញុំមកយកខ្ញុំទៅនៅជាមួយគាត់ទៅ បាទយកមកនៅជាមួយគាត់

ខ្ញុំបែកពីបងនៅពុកឬស្សីនឹងមក ខ្ញុំមកនៅជាមួយបងនៅកោះដាច់ឯណោះវិញ នៅពីរនាក់បងនឹង បងប្រុសរបស់ខ្ញុំឈ្មោះខ្លឹងនឹងណា។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះបងប្អូនទាំងប្រាំនាក់របស់អ៊ុំប្រុស បានស្លាប់អស់ប៉ុន្មាននាក់ហើយ?

ខ៖ បងប្អូនរបស់ខ្ញុំគាត់បានស្លាប់អស់បួននាក់ហើយ។

ក៖ អូ! បងប្អូនរបស់អ៊ុំប្រុសបានស្លាប់អស់បួននាក់ហើយ នៅតែអ៊ុំប្រុសហើយនឹងបងស្រី។ ហើយ អញ្ចឹងសំរាប់បងប្អូនទាំងបួននាក់ដែលបានស្លាប់នឹង តើពួកគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ?

ខ៖ គាត់ឈឺ គាត់មានជម្ងឺ ហើយគាត់បានស្លាប់ទៅ។

ក៖ ហើយអញ្ចឹង សំរាប់បងស្រីម្នាក់របស់អ៊ុំប្រុសដែលគាត់នៅពុកឬស្សីនឹង តើគាត់ធ្វើការងារអ្វីដែរ?

ខ៖ ខ្ញុំអត់ដែលបានទៅផង លឺតែគេនិយាយថាគាត់នៅជាមួយកូនប្រុសរបស់គាត់បងគេ ហើយលឺថាគាត់ដើរទិញស្ពៃៗទៅលក់ដូរ។

ក៖ អូ! អញ្ចឹងមានន័យថាគាត់ដើរទិញអីវ៉ាន់គេ យកមកលក់ដូរនៅនឹងផ្ទះ។

ខ៖ លក់ដូរនៅនឹងផ្ទះចឹងទៅ ធ្វើនំអីលក់នៅនឹងផ្ទះ។

ក៖ ហើយអញ្ចឹង សំរាប់ម្តាយរបស់អ៊ុំប្រុស តើគាត់មានឈ្មោះអ្វីដែរ អ៊ុំប្រុស?

ខ៖ ម្តាយរបស់ខ្ញុំគាត់មានឈ្មោះ យាយភួង។

ក៖ ហើយអញ្ចឹង តើអ៊ុំប្រុសនៅចាំទេថា ម្តាយរបស់អ៊ុំប្រុសគាត់បានកើតនៅពេលណា?

ខ៖ អូ! អត់ចាំតែម្តងខ្ញុំ អត់ចាំទេម្តាយខ្ញុំ។

ក៖ ហើយអញ្ចឹង តើម្តាយរបស់អ៊ុំប្រុសគាត់កើតនៅកន្លែងណា អ៊ុំប្រុសដឹងទេ?

ខ៖ ម្តាយរបស់ខ្ញុំគាត់កើតនៅភូមិវាលឃ្លាំងមឿងនឹង។

ក៖ អូ! អញ្ចឹងគាត់កើតនៅភូមិជាមួយអ៊ុំប្រុសបានកើតនឹងន៎! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើ ម្តាយរបស់អ៊ុំប្រុសគាត់ស្លាប់ហើយ ឬគាត់នៅមានជីវិតរស់នៅ?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លាប់បាត់ហើយ។

កៈ ហើយអញ្ចឹង ម្ដាយរបស់អ៊ុំប្រុសគាត់បានស្លាប់ប៉ុន្មានឆ្នាំហើយ អ៊ុំប្រុស?

ខៈ ម្ដាយរបស់ខ្ញុំគាត់ស្លាប់តាំងពីឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំពីរ ចិតសិបប្រាំបីនឹងមក។

កៈ អូ! អញ្ចឹងមានន័យថាគាត់បានស្លាប់ក្នុងជំនាន់ពលពត។ តើគេយកគាត់ទៅវាយចោល ឬមួយយ៉ាងណាដែរ អ៊ុំប្រុស?

ខៈ គាត់ចូលមកស្រុកវិញគាត់មានជម្ងឺ គាត់ឈឺ។

កៈ អូ! អញ្ចឹងមានន័យថាគាត់អត់បានត្រូវពលពតសំលាប់ទេ តែគាត់បានស្លាប់ដោយសារជំងឺ។ ហើយអញ្ចឹង តើម្ដាយរបស់អ៊ុំប្រុសគាត់បានស្លាប់ប្រហែលជាឆ្នាំណាដែរ?

ខៈ ចូលចិតសិបប្រាំបីនឹង ចិតសិបប្រាំពីរ ចិតសិបប្រាំបី។

កៈ ហើយអញ្ចឹង តើអ៊ុំប្រុសដឹងទេថាពេលដែលគាត់បានស្លាប់នឹង គាត់មានអាយុប៉ុន្មានឆ្នាំដែរ?

ខៈ អត់ដឹងទេ កាលគាត់ស្លាប់អត់ដឹងគាត់អាយុប៉ុន្មានទេ ព្រោះនៅបែកពីខ្ញុំដែរនឹង។

កៈ អូ! អញ្ចឹងមានន័យថា នៅពេលដែលម្ដាយរបស់អ៊ុំប្រុសបានស្លាប់ អ៊ុំប្រុសអត់បាននៅជិតគាត់ទេ។

ខៈ ខ្ញុំអត់បាននៅជិតគាត់ទេ ព្រោះខ្ញុំបានទៅជាមួយកងចល័ត គេបានកៀងទៅខាងស្រុកប្អូនខ្ញុំ។

កៈ អត់បាននៅជុំគ្នាគួរអោយស្ដាយណាស់អ៊ុំប្រុស។ ហើយអញ្ចឹងសំរាប់ម្ដាយរបស់អ៊ុំប្រុសគាត់កើតឆ្នាំខ្មែរ ឆ្នាំអីអ៊ុំប្រុសដឹងទេ?

ខៈ អត់ដឹងទេ បើកាលនឹងខ្ញុំនៅក្មេងៗមិនដឹងថាគាត់កើតឆ្នាំណាទេ ខ្ញុំនៅតូចៗពេក។

កៈ ហើយអញ្ចឹង សំរាប់ម្ដាយរបស់អ៊ុំប្រុស កាលគាត់នៅរស់ តើគាត់ប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមជីវិតដែរ អ៊ុំប្រុស?

ខៈ កាលគាត់នៅជួបជុំជាមួយខ្ញុំអីនឹង គាត់ទិញបន្លែដូចជាល្ហុង ទិញសណ្ដាន់ យកទៅលក់នៅភ្នំពេញ ទិញនៅក្នុងភូមិយើងនឹង ហើយយកទៅលក់នៅភ្នំពេញ។

ក៖ អូ! អញ្ចឹងគាត់ទិញបន្លែពីក្នុងភូមិយកទៅលក់នៅភ្នំពេញ ហើយបានលុយមកផ្គត់ផ្គង់គ្រួសារខ្លះទៅ ហើយយកលុយខ្លះទៅទិញតទៀតទៅ។

ខ៖ ព្រោះម្ដាយរបស់ខ្ញុំហើយនឹងឪពុករបស់ខ្ញុំគាត់លែងលះគ្នា ខ្ញុំនៅជាមួយគាត់បានខ្ញុំដឹងពីប្រវត្តិរកស៊ីរបស់គាត់ មុខរបរទិញដូរដូចជា កន្ទុច ផ្លែល្ហុង ត្រួយបាសអីនឹង គាត់ចេះតែដើរបេះយកទៅលក់ទៅ។

ក៖ ហើយអញ្ចឹង សំរាប់ម្ដាយរបស់អ៊ុំប្រុសគាត់មានចរិតយ៉ាងដូចម្ដេចដែរអ៊ុំប្រុស ដូចថាអត្តចរិត គាត់ស្លូតបូត សុភាពរាបសារ ឬមួយគាត់កាច ឬក៏ម៉េចដែរអ៊ុំ?

ខ៖ គាត់ស្លូតទេ គាត់មិនដែលអីគាត់ទេ គាត់មិនដែលកាចណាគាត់ទេ តាំងពីខ្ញុំនៅជាមួយគាត់ គាត់ធម្មតាគាត់ស្លូតជាមួយកូនចៅជាមួយញាត្តិមិត្តបងប្អូនជិតខាងនឹង គាត់មិនដែលមានទំនាស់អីជាមួយបងប្អូនជិតខាង ហើយជាមួយកូនចៅក៏មិនដែរមានដែរ គាត់ស្រួលគាត់ស្លូត។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំប្រុស តើគាត់មានឈ្មោះអ្វីដែរ អ៊ុំប្រុស?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះ គ្រួច ចិន។

ក៖ គ្រួច ចិន!

ខ៖ ឪពុកគាត់ឈ្មោះគ្រួច ហើយគាត់ឈ្មោះចិន ហើយអញ្ចឹងបានឪពុកខ្ញុំដាក់ឈ្មោះ ចិន ជឹម។

ក៖ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំប្រុសគាត់បានកើតនៅណាដែរ អ៊ុំប្រុសដឹងទេ?

ខ៖ ឪពុកគាត់គាត់កើតនៅពុកឫស្សីរឹងណោះ ស្រុកកំណើតគាត់នៅពុកឫស្សី។

ក៖ អូ! គាត់កើតនៅពុកឫស្សី។ ហើយអញ្ចឹង ពុកឫស្សីនឹងស្ថិតនៅក្នុងខេត្តណាដែរ អ៊ុំប្រុស?

ខ៖ នៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលដែរ។

ក៖ អូ! ស្ថិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ហើយអញ្ចឹងសំរាប់ស្រុកកំណើតឪពុករបស់អ៊ុំប្រុសខុសគ្នាពីស្រុកកំណើតរបស់ម្ដាយរបស់អ៊ុំប្រុស?

ខ៖ បាទ ខុសគ្នា គាត់នៅក្នុងស្រុកជាមួយគ្នានឹង តែគ្រាន់តែនៅភូមិផ្សេងគ្នា។

កៈ អូ! អញ្ចឹងមានន័យថា ស្រុកឃុំជាមួយគ្នា តែភូមិផ្សេងគ្នា។ ហើយអញ្ចឹង តើភូមិពួកគាត់នៅឆ្ងាយពីគ្នាទេ អ៊ុំប្រុស?

ខៈ នៅឆ្ងាយពីគ្នា។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំប្រុសគាត់កើតឆ្នាំខ្មែរឆ្នាំអ្វី  តើអ៊ុំប្រុសដឹងទេ?

ខៈ អត់ដឹងទេ ព្រោះអីនៅតូចៗមានដឹងអី ហើយត្រូវបែកពីគាត់ទៀត ម្ដាយរបស់ខ្ញុំលែងលះជាមួយគាត់ហើយខ្ញុំតាមម្ដាយរបស់ខ្ញុំ។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ អ៊ុំប្រុសដឹងទេថា គាត់នៅមានជីវិតរស់នៅ ឬមួយគាត់បានស្លាប់ហើយ?

ខៈ គាត់ស្លាប់ហើយ គាត់បានស្លាប់មុនម្ដាយរបស់ទៀតណោះ។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ៊ុំប្រុសគាត់ស្លាប់ប្រហែលឆ្នាំណាដែរ អ៊ុំប្រុសមាននៅចាំទេ?

ខៈ អត់ចាំទេ។

កៈ ហើយអញ្ចឹង
តើឪពុករបស់អ៊ុំប្រុសគាត់បានស្លាប់មុនម្ដាយរបស់អ៊ុំប្រុសប្រហែលប៉ុន្មានឆ្នាំ?

ខៈ គាត់បានស្លាប់តាំងពីមុនពលពតទៀតឯណោះ។

កៈ អូ! អញ្ចឹងគាត់ស្លាប់មុនឆ្នាំចិតប្រាំទៀត។ ហើយអញ្ចឹង ឪពុករបស់អ៊ុំប្រុសគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ៊ុំប្រុស?

ខៈ ឪពុករបស់ខ្ញុំគាត់ឈឺដែរនឹង។

កៈ ហើយអញ្ចឹង តើឪពុករបស់អ៊ុំប្រុសគាត់កើតជម្ងឺអ្វីដែរ អ៊ុំប្រុសដឹងទេ?

ខៈ អត់ដឹងផង ព្រោះអីបែកគ្នា។

កៈ អូ! អ៊ុំប្រុសអត់ដឹងផងព្រោះអីនៅបែកគ្នាពីគាត់។

ខៈ នឹងហើយអត់នៅជុំគ្នាផង នៅបែកគ្នាពីគាត់។

កៈ ហើយអញ្ចឹង កាលដែលឪពុករបស់អ៊ុំប្រុសនៅរស់ តើគាត់ប្រកបមុខរបរអ្វើដែរ អ៊ុំប្រុស?

ខ៖ ឪពុកខ្ញុំគាត់ធ្វើស្រែចំការ គាត់ធ្វើស្រូវប្រាំង តែព្រលឹមឡើងគាត់ទៅហើយ ដល់ព្រលប់ឡើងបានមកវិញ គាត់ទៅមើលស្រូវមើលអី ហើយដាក់ទឹកចូលស្រែអីហើយបានគាត់ត្រឡប់មកវិញ។

ក៖ ហើយអញ្ចឹងសំរាប់ឪពុករបស់អ៊ុំប្រុសគាត់មានចរិតយ៉ាងម៉េចដែរ?

ខ៖ គាត់ក៏ស្លូតដែលនឹងជាមួយកូនចៅបងប្អូន តាមខ្ញុំធ្លាប់រស់នៅជាមួយគាត់កាលតូចៗ។

ក៖ ហើយអញ្ចឹង តើមូលហេតុអ្វីដែលបានជាគាត់លែងលះជាមួយម្ដាយរបស់អ៊ុំប្រុស?

ខ៖ មិនដឹងជាយ៉ាងម៉េចដែរនឹង ព្រោះអីកាលនឹងខ្ញុំនៅតូច។

ក៖ អូ! អញ្ចឹងអ៊ុំប្រុសនៅតូច អត់ចាំទេ។ ហើយអញ្ចឹង តើអ៊ុំប្រុសមាននៅចាំសាច់រឿងអ្វីខ្លះអំពីឪពុកម្ដាយរបស់អ៊ុំប្រុស កាលអ៊ុំប្រុសនៅតូចៗ? ដូចជា អ៊ុំប្រុសធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ទេ?

ខ៖ មានអី អត់មានអីទេ ឪពុកម្ដាយគាត់ចេះតែរស់នៅជាមួយគាត់ធម្មតាអត់ដែលមានរឿងស្អីជាមួយគាត់ទេ សុខសប្បាយជាមួយគាត់នឹង អត់ដែលមានបញ្ហាអីជាមួយគាត់ទេ យើងនៅតូចៗ យើងរស់ក្រោមការថែរក្សារបស់គាត់។

ក៖ ហើយអញ្ចឹង សំរាប់ឪពុកម្ដាយរបស់អ៊ុំប្រុសគាត់ធ្លាប់ប្រាប់អ៊ុំប្រុសទេ អ៊ំពីជីវិតរបស់គាត់កាលគាត់នៅក្មេងៗ? ពេលដែលគាត់នៅជាមួយអ៊ុំប្រុសគាត់ធ្លាប់ប្រាប់អ៊ុំប្រុសទេថា កាលឪពុកនៅក្មេង ពុកធ្លាប់ធ្វើនេះធ្វើនោះ?

ខ៖ អត់ទេ គាត់អត់ដែលមានប្រាប់ទេ។

ក៖ ហើយអញ្ចឹង តើអ៊ុំប្រុសមានស្គាល់ឈ្មោះជីដូនជីតាខាងម្ដាយទេ?

ខ៖ ពិបាកណាស់ខ្ញុំនៅតូចៗនឹងអត់មានចាំ អត់ដែលលឺគាត់និយាយអីផង។

ក៖ អូ! អញ្ចឹងអត់ដែលលឺគាត់និយាយពីជីដូនជីតា។

ខ៖ អត់មានដែលលឺគាត់និយាយពីជីដូនជីតា។

ក៖ ហើយអញ្ចឹងបានន័យថាពេលដែលអ៊ុំប្រុសនៅតូចៗនឹង អ៊ុំប្រុសអត់ដែលបានជួបជាមួយជីដូនជីតាទេ?

ខ៖ ជួបតែជីដូនទេខាងម្តាយរបស់ខ្ញុំនឹង។

ក៖ ហើយអញ្ចឹងសំរាប់ជីដូនខាងម្តាយរបស់អ៊ុំប្រុសគាត់មានឈ្មោះអ្វីដែរអ៊ុំប្រុស?

ខ៖ ជីដូនខាងម្តាយរបស់ខ្ញុំគាត់ឈ្មោះ យាយជិន។

ក៖ អញ្ចឹងមានន័យថាម្តាយរបស់ម្តាយរបស់អ៊ុំប្រុសគាត់ឈ្មោះយាយជិន។

ខ៖ ហើយបើឪពុករបស់ម្តាយរបស់ខ្ញុំ អត់ស្គាល់ទេ។

ក៖ ហើយអញ្ចឹង តើគាត់បានកើតនៅកន្លែងណាដែរអ៊ុំប្រុសនៅចាំទេ?

ខ៖ ពិបាកចាំណាស់ ព្រោះអីខ្ញុំនៅតូចៗ។

ក៖ ហើយអញ្ចឹង សំរាប់ជីដូនរបស់អ៊ុំប្រុសនឹង គាត់បានស្លាប់ហើយ អ៊ុំប្រុស?

ខ៖ គាត់ស្លាប់ហើយ គាត់ស្លាប់តាំងពីមុនម្តាយខ្ញុំ មុនឪពុកខ្ញុំទៀតណោះ។

ក៖ ហើយអញ្ចឹង អ៊ុំប្រុសនៅចាំថា គាត់បានស្លាប់នៅពេលណាទេ អ៊ុំប្រុស?

ខ៖ យូរហើយ យូរឆ្នាំហើយ តាំងពីមុនម្តាយខ្ញុំទៀតណោះ។

ក៖ ហើយអញ្ចឹង
កាលអ៊ុំប្រុសនៅក្មេងៗតើអ៊ុំប្រុសធ្លាប់មានអនុស្សាវរីយ៍អ្វីជាមួយលោកយាយទេ?

ខ៖ អត់ដែលមានទេ យាយរបស់ខ្ញុំនឹងមិនសូវបានស្គាល់គាត់ច្បាស់ផងទេ
នៅជាមួយម៉ែមែន តែមិនសូវបានស្គាល់យាយច្បាស់ទេ។

ក៖ អញ្ចឹងមានន័យថា យាយរបស់អ៊ុំប្រុសគាត់អត់នៅជាមួយម្តាយទេ
បានជាអ៊ុំប្រុសមិនសូវបានជួបគាត់។

ខ៖ ខាងឪពុករបស់ខ្ញុំក៏ចឹងដែរ ជីដូនជីតាខ្ញុំនៅពុកឫស្សីខាងឪពុករបស់ខ្ញុំ
ស្គាល់ជីដូនបានជួបគាត់ម្តងៗដែរ
នៅពេលបុណ្យទានពេលដែលឪពុករបស់ខ្ញុំគាត់ស្លាប់នឹង ខ្ញុំទៅ។

ក៖ ហើយអញ្ចឹង សំរាប់ជីដូនជីតាខាងឪពុករបស់អ៊ុំប្រុសគាត់មានឈ្មោះអ្វីខ្លះ
អ៊ុំប្រុសនៅចាំទេ?

ខ៖ ជីដូនជីតាខាងឪពុករបស់ខ្ញុំគាត់ឈ្មោះតាគ្រួច យាយទឹម។

កៈ ហើយអញ្ចឹង
តើជីដូនជីតាខាងឪពុករបស់អ៊ុំប្រុសគាត់កើតនៅពេលណាអ៊ុំប្រុសនៅចាំទេ?

ខៈ អត់ចាំទេ។

កៈ អត់ចាំទេ! ហើយអញ្ចឹង សំរាប់ជីដូនជីតាខាងឪពុករបស់អ៊ុំប្រុសនឹង
ពួកគាត់កើតនៅកន្លែងណាដែរអ៊ុំប្រុស?

ខៈ បើសួរខ្ញុំអត់ដឹងទេ តែបើតាមខ្ញុំដឹងគាត់នៅភូមិពុកឫស្សីនឹង
គាត់កើតនៅនឹងភូមិពុកឫស្សី។

កៈ ហើយអញ្ចឹង សំរាប់ជីដូនជីតាខាងឪពុករបស់អ៊ុំប្រុសគាត់បានស្លាប់នៅពេលណា
អ៊ុំប្រុសនៅចាំទេ?

ខៈ អត់ចាំឆ្នាំទេ មិនដឹងថាគាត់ស្លាប់នៅឆ្នាំណាទេ។

កៈ ហើយអញ្ចឹង តើជីដូនជីតាខាងឪពុករបស់អ៊ុំប្រុសពួកគាត់បានស្លាប់នៅកន្លែងណាដែរ
អ៊ុំប្រុស?

ខៈ ពួកគាត់ស្លាប់នៅភូមិពុកឫស្សីនឹងម៉ង គាត់ស្លាប់នៅនឹងស្រុកកំណើតគាត់។

កៈ អូ! អញ្ចឹងមានន័យថា គាត់កើតនៅនឹង ហើយគាត់ស្លាប់ក៏នៅនឹងដែរ
គាត់អត់មានបានចេញទៅណាទេ។ ហើយអញ្ចឹង
អ៊ុំប្រុសធ្លាប់មានអនុស្សាវរីយ៍អីពេលទៅលេងគាត់
គាត់បានធ្វើអីអោយអ៊ុំប្រុសសប្បាយចិត្តទេអ៊ុំប្រុស?

ខៈ ខ្ញុំបានតែទៅនៅពលដែលគាត់ស្លាប់នឹងណា ទៅបុណ្យគាត់នឹង
ហើយបូជាសពគាត់នឹង។

កៈ ហើយអញ្ចឹងសំរាប់អ៊ុំប្រុស
បានរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយអ៊ុំប្រុស?

ខៈ មិនដឹងជាប៉ុន្មានឆ្នាំទេ ខ្ញុំរស់នៅទីនេះតាំងពីឆ្នាំចិតសិបប្រាំបួនមក។

កៈ ហើយអញ្ចឹង តើអ៊ុំប្រុសមានបងប្អូនសាច់ញាត្តិដែលរស់នៅក្រៅប្រទេសខ្មែរទេ
អ៊ុំប្រុស?

ខៈ ខ្ញុំអត់មានទេ។

កះ អូ! អត់មានទេ មានតែនៅក្នុងប្រទេសយើងនឹង។ ហើយអញ្ចឹង
សំរាប់ភរិយារបស់អ៊ុំប្រុសគាត់មានឈ្មោះអ្វីដែរ អ៊ុំប្រុស?

ខះ ភរិយារបស់ខ្ញុំគាត់មានឈ្មោះ ស៊ឹម យ៉ន។

កះ ស៊ឹម យ៉ន! ហើយអញ្ចឹង តើអ៊ុំប្រុសបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំណាដែរ អ៊ុំប្រុស?

ខះ ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួន។

កះ អូ! ចេញមកពីសម័យពលពតវិញឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួន។ ហើយអញ្ចឹង មកដល់សព្វថ្ងៃនេះ តើអ៊ុំប្រុសរៀបការជាមួយគាត់បានប៉ុន្មានឆ្នាំហើយ?

ខះ អត់ដឹងប៉ុន្មានទេ។

កះ ហើយអញ្ចឹងសំរាប់ពេលដែលអ៊ុំប្រុសបានរៀបការ តើអ៊ុំប្រុសមានអាយុប៉ុន្មានឆ្នាំហើយ អ៊ុំប្រុស?

ខះ អត់ចាំទេ។

កះ
ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍មួយនឹងត្រូវបានរៀបចំឡើងដោយឪពុកម្ដាយរបស់អ៊ុំប្រុស ឬមួយអ៊ុំប្រុសរៀបចំដោយខ្លួនឯង?

ខះ នឹងម្ដាយមីងហើយនឹងបងប្អូនគាត់ជាអ្នកជួយរៀបចំអោយ
ព្រោះអីម្ដាយរបស់ខ្ញុំគាត់ស្លាប់អស់ហើយ មាននរណាគេទេ មានតែម្ដាយមីង
បងជីដូនមួយ គាត់ជាអ្នកផ្ដួចផ្ដើម។

កះ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹងមានដូចជាថ្លៃជំនួនទេ អ៊ុំប្រុស?

ខះ អត់មានទេកាលជំនាន់នឹង អត់មានទេ។

កះ អូ! អត់មានទេ យើងរៀបចំតិចតួចអីចឹងទៅ សែនព្រេនអីចឹងទៅ។ ហើយអញ្ចឹង
តើអ៊ុំប្រុសប្រាប់ខ្ញុំបានទេ ពេលដំបូងដែលអ៊ុំប្រុសបានជួបជាមួយអ៊ុំស្រីនៅពេលណាដែរ អ៊ុំប្រុស?

ខះ ពេលមករៀបនឹងនៅឆ្នាំចិតសិបប្រាំបួន។

កៈ តែលើកដំបូងបំផុតដែលស្គាល់គ្នានឹង ឬម្ដាយមីងគាត់អ្នកណែនាំអោយស្គាល់តែម្ដង ឬមួយអ៊ុំប្រុសបានឃើញគាត់នៅភូមិនេះឬភូមិនោះ?

ខៈ នឹងធ្លាប់ស្គាល់តាំងពីដើម។

កៈ ហើយអញ្ចឹង សំរាប់ចំណងអាពាហ៍ពិពាហ៍អ៊ុំប្រុសហើយនឹងអ៊ុំស្រី តើមានកូនចំនួនប៉ុន្មាននាក់ដែរ អ៊ុំប្រុស?

ខៈ សព្វថ្ងៃកូនទាំងអស់បួននាក់។

កៈ កូនទាំងអស់បួននាក់! ហើយអញ្ចឹង តើអ៊ុំប្រុសមានកូនប្រុសប៉ុន្មាននាក់ ហើយស្រីប៉ុន្មាននាក់ដែរ?

ខៈ ខ្ញុំមានកូនស្រីពីរនាក់ ហើយប្រុសពីរនាក់។

កៈ ហើយអញ្ចឹង តើអ៊ុំប្រុសអាចជួយរៀបរាប់ឈ្មោះកូនទាំងបួននាក់បានទេ អ៊ុំប្រុស?

ខៈ កូនទីមួយឈ្មោះ ជឹម យ៉ាន ហើយកូនទីពីរឈ្មោះ ជឹម ចៀន ហើយកូនទីបីឈ្មោះ ជឹម សាអែម ហើយកូនទីបួនឈ្មោះ ជឹម ចាន់ថន។

កៈ ហើយអញ្ចឹង សព្វថ្ងៃនេះកូនទាំងបួនរបស់អ៊ុំប្រុសពួកគាត់បានរៀបការអស់ហើយ ឬក៏នៅទេ អ៊ុំប្រុស?

ខៈ សព្វថ្ងៃនេះរៀបការបានស្រីពីរនាក់ នៅកូនប្រុសពីរមិនទាន់រៀបការទេ។

កៈ អូ! កូនប្រុសអ៊ុំប្រុសពីរនាក់មិនទាន់បានរៀបការទេ
តែកូនស្រីពីរនាក់បានរៀបការរួចហើយ។
ហើយអញ្ចឹងកូនទីប៉ុន្មានខ្លះដែលបានរៀបការហើយនឹង អ៊ុំប្រុស?

ខៈ ស្រីទីមួយបងគេ ហើយនឹងស្រីទីបី។

កៈ ហើយអញ្ចឹង សំរាប់ថ្ងៃនេះអ៊ុំប្រុសមានចៅហើយឬនៅទេ អ៊ុំប្រុស?

ខៈ សព្វថ្ងៃនេះខ្ញុំមានចៅរួចហើយ។

កៈ ហើយអញ្ចឹង តើអ៊ុំប្រុសមានចៅចំនួនប៉ុន្មាននាក់ហើយ អ៊ុំប្រុស?

ខៈ ខ្ញុំមានចៅចំនួនប្រាំមួយនាក់ហើយ។

កៈ អូ! ច្រើនផងអ៊ុំប្រុស!

ខ៖ កូនរបស់កូនស្រីបងមួយនាក់ ហើយនឹងកូនរបស់កូនស្រីទីបីនឹងប្រាំនាក់។

ក៖ អូ! អញ្ចឹងចៅប្រាំមួយនាក់ ហើយកូនរបស់បងធំនឹងមានតែម្នាក់ទេ ហើយទីបីនឹងដល់ប្រាំនាក់  ឯណោះ។ ហើយអញ្ចឹង តើអ៊ុំប្រុសអាចជួយរៀបរាប់ឈ្មោះចៅទាំងប្រាំមួយនាក់នឹងបានទេ?

ខ៖ ឪពុកឈ្មោះវុទ្ធថា ហើយកូនឈ្មោះវុទ្ធី នឹងចៅបងគេ ហើយកូនរបស់កូនខ្ញុំទីបីឈ្មោះ ភា លីនដា ហើយបន្ទាប់មក ភា ផាន់នី ហើយបន្ទាប់មកទៀត ភា ភក្ត្រា ហើយមកទៀត ភា ផាន់ណា ហើយនឹង ភា វ៉ាន់ណេត នឹងទើបនឹងកើតបានប្រាំប្រាំមួយខែ។

ក៖ អូ! អញ្ចឹងចៅច្រើនណាស់អ៊ុំ អញ្ចឹងទៅអនាគតទៅចៅប្រហែលជាច្រើនជាងនឹងទៅទៀត ព្រោះអីនៅកូនប្រុសដ៏ពីរនាក់ទៀតណោះ ពេលដែលពួកគាត់រៀបការហើយគាត់ចង់បានកូនទៀតហើយ អញ្ចឹងអ៊ុំប្រុសនឹងបានចៅទៀតហើយ។ ហើយអញ្ចឹង សំរាប់អ៊ុំប្រុសចេះអាននិងសរសេរអក្សរខ្មែរទេ អ៊ុំប្រុស?

ខ៖ មិនសូវចេះស្ទាត់ប៉ុន្មានទេ តែចេះអាន ចេះមើល។

ក៖ ហើយអញ្ចឹង តើអ៊ុំប្រុសចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ?

ខ៖ អត់ចេះទេ។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំប្រុសចេះអានអក្សរខ្មែរចឹង តើអ៊ុំប្រុសបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ខ្ញុំពីដើមកូនសិស្សលោករៀននៅក្នុងវត្ត។

ក៖ ហើយអញ្ចឹង តើអ៊ុំប្រុសរៀននៅក្នុងវត្តណាដែរ អ៊ុំប្រុស?

ខ៖ ខ្ញុំរៀននៅវត្ត ក្រពុំពេជ្រ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល។

ក៖ វត្តក្រពុំពេជ្រ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល។ ហើយអញ្ចឹង កាលពីក្មេងៗមក អ៊ុំប្រុសធ្លាប់មានមិត្តភក្តិជិតស្និតទេអ៊ុំប្រុស?

ខ៖ ខ្ញុំមានមិត្តភក្តិជិតស្និតបីនាក់ដែរ តែដែលជិតស្និតជាងគេមានតែម្នាក់ទេ។

ក៖ ហើយអញ្ចឹង មិត្តភក្តិជិតស្និតរបស់អ៊ុំប្រុសនឹងគាត់មានឈ្មោះអ្វីដែរ អ៊ុំប្រុស?

ខ៖ កាលពីដើមនៅកោះដាច់ឪពុករបស់គាត់ឈ្មោះសុខ ហើយគាត់ឈ្មោះកុល ។

ក៖ អូ! អញ្ចឹងគាត់ឈ្មោះ សុខ កុល។ ហើយអញ្ចឹង
សព្វថ្ងៃនេះតើអ៊ំប្រុសដឹងទេថាគាត់មានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ មិនដឹងជាអាយុប៉ុន្មានទេ។

ក៖ ហើយអញ្ចឹង តើគាត់មានអាយុប្រហាក់ប្រហែលអ៊ំប្រុសដែរទេ?

ខ៖ ទេ គាត់មានអាយុប្អូនខ្ញុំទេ។

ក៖ ហើយអញ្ចឹង តើគាត់ប្អូនអ៊ំប្រុសប្រហែលប៉ុន្មានឆ្នាំដែរ អ៊ំប្រុស?

ខ៖ គាត់ប្អូនខ្ញុំប្រហែលជាពីរបីឆ្នាំទេ។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះគាត់ប្រកបមុខរបស់អ្វីដែរ
អ៊ំប្រុសមានបានដំណឹងគាត់ខ្លះទេអ៊ំ?

ខ៖ គាត់ទៅនៅឯខេត្តស្ទឹងត្រែង តែមិនដឹងមុខរបរគេខាងអីទេ។

ក៖ អូ! គាត់ទៅនៅឯខេត្តស្ទឹងត្រែង! ហើយអញ្ចឹង តើអ៊ំប្រុសបែកពីគាត់យូរហើយមែនទេ?

ខ៖ បែកគ្នាយូរហើយ បែកគ្នាតាំងពីមុនពលពតទៀតណោះ។

ក៖ អូ! បែកគ្នាទាំងពីជំនាន់ពលពត។ ហើយអញ្ចឹង
លែងបានទំនាក់ទំនងគ្នាសោះតែម្តងឬអ៊ំប្រុស?

ខ៖ ជួនកាលគាត់មកដែលនឹងព្រោះអីបងប្អូនគាត់នៅលើកោះនឹង
ចឹងហើយគាត់ឧស្សាហ៍មកដែលនឹង។

ក៖ ហើយអញ្ចឹង ពេលដែលគាត់មកអញ្ចឹង តើគាត់មានឧស្សាហ៍ចូលមកលេងអ៊ំប្រុសទេ?

ខ៖ ពេលគាត់មក គាត់ឧស្សាហ៍ចូលមកលេងខ្ញុំដែរ។

ក៖ អូ! អញ្ចឹងល្អហើយនៅទំនាក់ទំនងគ្នាអត់អីទេអ៊ំប្រុស។ ហើយអញ្ចឹង កាលពីនៅក្មេងៗ
តើ អ៊ំប្រុសចូលចិត្តធ្វើអ្វីខ្លះជាមួយគាត់ដែរ អ៊ំប្រុស?

ខ៖ ខ្ញុំនៅវត្តជាមួយគ្នា នៅបួសជាមួយគ្នា នៅស្រុកកំណើតជាមួយគ្នា
ហើយពេលសឹកមកនឹង ដើរលេងជាមួយគ្នា

ពេលយើងសឹងពីលោកមកយើងដើរលេងជាមួយគ្នា ព្រោះអីយើងចិត្តត្រង់ហើយចិត្តល្អដូចគ្នា។

ក៖ ហើយអញ្ចឹង សព្វថ្ងៃនេះអ៊ុំប្រុសមានធ្វើស្រែចំការទេ អ៊ុំប្រុស?

ខ៖ ខ្ញុំអត់មានទេសព្វថ្ងៃនេះ។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំប្រុសសព្វថ្ងៃ តើអ៊ុំប្រុសធ្វើអ្វីដែរដើម្បីចិញ្ចឹងជីវិត?

ខ៖ រាល់ថ្ងៃដើររកអេតចាយ ដើរទៅរកនៅតាមភូមិគេផ្សេងៗ ដើររកដូចជា កំប៉ុងបៀរ កំប៉ុងទឹកក្រូច ហើយដបទឹកសុទ្ធនឹង បានមកចេះតែសន្សំយកទៅលក់ទៅ។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំប្រុស តាំងពីក្មេងរហូតមកដល់ពេលនេះ តើអ៊ុំប្រុសគិតថាជីវិតរបស់ អ៊ុំប្រុសមានការផ្លាស់ប្តូរទេ?

ខ៖ គ្មានផ្លាស់ប្តូរទៅណាទេ មុខរបរ នៅតែប៉ុណ្ណឹង ព្រោះអីកំលាំងយើងចាស់ហើយមិនដឹងថាទៅរកអីទេ បើយើងមិនរកអានឹងទេ យើងវាអត់មានអីហូបទេ ចឹងហើយចេះតែរកទៅ។

ក៖ ហើយអញ្ចឹងសំរាប់ម្ហូបវា តើអ៊ុំប្រុសចូលចិត្តហូបម្ហូបអ្វីជាងគេដែរ អ៊ុំប្រុស?

ខ៖ ខ្ញុំហូបតាមនឹងឃើញអញ្ចឹងទៅ ដូចជាសម្លរអីចឹងទៅ ជូនកាលទៅត្រីអាំងអីចឹងទៅ។

ក៖ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរដូចជាបោះឈូង បោះអង្គញ់ ទាញព្រ័ត្រ តើអ៊ុំប្រុសចូលចិត្តលេងទេ?

ខ៖ ពីដើមមកខ្ញុំចូលចិត្តអារឿងលេងបោះឈូង លាក់កន្សែង បោះអង្គញ់អីនឹង ពីដើមនឹងចូលចិត្តលេងណាស់ ហើយឥលូវនឹងអោយតាមានគេលេងខ្ញុំចូលចិត្តលេងណាស់។

ក៖ ហ្នឹងហើយ ត្រូវហើយ នឹងជាល្បែងប្រជាប្រិយខ្មែរយើងអត់មានទៅជាប់ពាក់ព័ន្ធទោសអីទេ គ្រាន់តែយើងលេងដើម្បីអបអរចូលឆ្នាំខ្មែរ។

ខ៖ ចូលឆ្នាំខ្មែរយើងនាំចូលថៅលេង បងប្អូនជិតខាងយើងលេងទៅ សប្បាយទាំងអស់គ្នា។

ក៖ ហើយអញ្ចឹងសំរាប់បទចម្រៀង តើមានបទចម្រៀងណាដែលអ៊ុំប្រុសចូលចិត្តស្តាប់ទេ អ៊ុំប្រុស?

ខ៖ ខ្ញុំសព្វថ្ងៃនេះចូលចិត្តស្តាប់បទពីដើមៗដូចជាបទស៊ីន ស៊ីសាម៉ុត រស់ សេរីសុទ្ធា។

ក៖ តាមពិតសំរាប់ខ្ញុំចូលចិត្តចឹងដែរ បើបទសម័យឥលូវមិនសូវស្តាប់ដែរ។ ហើយអញ្ចឹង តើនៅក្នុងក្រុមគ្រួសាររបស់អ៊ុំប្រុសមាននរណាម្នាក់ដែលគាត់ចេះលេងឧបករណ៍ភ្លេងទេ?

ខ៖ អត់មានទេ អត់មានសោះតែម្តង។

ក៖ អត់មានទេអ៊ុំប្រុស! ហើយអញ្ចឹង តើផ្ទះរបស់អ៊ុំប្រុសកាលដែលអ៊ុំប្រុសនៅតូចមានលក្ខណៈយ៉ាងម៉េចដែរអ៊ុំប្រុស?

ខ៖ ផ្ទះខ្ញុំពីដើមតូចដែរនឹង ផ្ទះទាម ហើយផ្ទះនេះអង្គការគេជួយទេ។

ក៖ អូ! អញ្ចឹងកាលពីអ៊ុំប្រុសនៅតូចនឹងផ្ទះទាម។ ហើយអញ្ចឹង តើផ្ទះរបស់អ៊ុំប្រុសកាលនៅតូចនឹង ប្រក់ដំបូលអ្វីដែរ អ៊ុំប្រុស?

ខ៖ ផ្ទះនឹងប្រក់ដំបូលស្លឹក។

ក៖ អូ! ប្រក់ដំបូលស្លឹងត្នោតយើង។ ហើយចុះជញ្ជាំងបានអីយកមកបាំងដែរ អ៊ុំប្រុស?

ខ៖ ជញ្ជាំងនឹងយកធាងដូងយកមកវាយ។

ក៖ អូ! យកធាងដូងមកវាយគាប់ទៅ។ ហើយអញ្ចឹង សំរាប់ផ្ទះដែលអ៊ុំនៅពីតូចនឹង ផ្ទះនឹងឪពុកអ៊ុំប្រុសគាត់ជាអ្នកធ្វើ ឬមួយគាត់ជួលគេអោយធ្វើអោយ?

ខ៖ ផ្ទះទាមរបស់ខ្ញុំពីដើមបងប្អូនគេជួយ កូនក្មួយគេជួយធ្វើ ស្តីអោយគេជួយធ្វើ។

ក៖ អូ! អញ្ចឹងអោយបងប្អូនជួយធ្វើជាមួយឪពុករបស់អ៊ុំប្រុសទៅ។

ខ៖ បងប្អូនជីដូនមួយខ្ញុំនឹងណា។

ក៖ អញ្ចឹង ផ្ទះកាលអ៊ុំប្រុសនៅពីតូចនឹង ឪពុករបស់អ៊ុំប្រុសគាត់ជាអ្នកធ្វើ ឬមួយអ៊ុំប្រុសធ្វើខ្លួនឯង?

ខ៖ ផ្ទះនឹងខ្ញុំធ្វើខ្លួនឯង។

ក៖ អូ! អញ្ចឹងបងប្អូនជីមួយ ហើយអ៊ុំប្រុសអ៊ុំស្រីចេះតែមកជួយ។

ខ៖ បានស្អីបងប្អូន ប្អូនថ្លៃអោយមកជួយ។

ក៖ ហើយអញ្ចឹង សំភារៈសំរាប់ធ្វើផ្ទះមួយនឹងបានមកពីណាដែរ អ៊ុំប្រុស យើងទិញគេ ឬមួយយើងទៅរកដោយខ្លួនឯង?

ខ៖ សំភារៈទាំងអស់នឹងដូចថា ខ្ញុំរកបានចឹងទៅផ្សំគ្នាទៅណា បានធ្វើទៅ
ដល់ពេលវាខូចរបស់ខ្ញុំ ចាស់ៗអស់ទៅ បានអង្គការគេជួយ។

ក៖ ហើយអញ្ចឹង តើនរណាគេជាអ្នកបង្រៀនអ៊ុំប្រុសអោយធ្វើផ្ទះមួយនឹងដែរ អ៊ុំប្រុស?

ខ៖ អត់មានបានធ្វើខ្លួនឯងទេ ដូចថាអង្គការគេជួយនឹង គេមានអ្នកនៅក្នុងស្រុកនឹងណា
គាត់ជាអ្នកទទួលខុសត្រូវមើលផ្ទះប្រជាជនណាអត់ៗចឹង ហើយពេលនឹង
គាត់នឹងអ្នកស្នើរអោយអង្គការនឹងមកជួយ បានគាត់នឹងអ្នកជួយដឹកនាំមក។

ក៖ ហើយអញ្ចឹង អ៊ុំប្រុសមានជំនាញដែលបន្តវេនពីក្រុមគ្រួសារដូចជា វេញវល្លិ៍ផ្តៅ
ជំនាញធ្វើស្ករត្នោត ដែរទេអ៊ុំប្រុស?

ខ៖ អត់មានទេសំរាប់ខ្ញុំនោះ។

ក៖ ហើយអញ្ចឹង តើជីវិតរបស់អ៊ុំប្រុសបានឆ្លងកាត់សម័យសង្គ្រាមដែរមែនទេ?

ខ៖ បាទ ខ្ញុំនៅជាមួយម្តាយទៅខាងបងប្អូនខ្ញុំនងស្រែណោះ។

ក៖ ហើយអញ្ចឹង កាលជំនាន់ពលពតនឹងអ៊ុំប្រុសនៅឯណាដែរ
ហើយគេអោយអ៊ុំប្រុសធ្វើអ្វីដែរ?

ខ៖ គេអោយទៅរែកដីកាប់ដីធ្វើទំនប់។

ក៖ ហើយអញ្ចឹង កាលជំនាន់ពលពតនឹង អ៊ុំប្រុសមានការលំបាកខ្លាំងទេ អ៊ុំប្រុស?

ខ៖ ជំនាន់នឹង នរណាក៏ដូចនរណាដែលសុទ្ធតែពិបាកដូចគ្នា
ចុះក្នុងទឹកលីដីជុំទប់ទំនប់ភ្លឺស្រែ។

ក៖ ហើយអញ្ចឹង សំរាប់អ៊ុំប្រុសវិញ មានពេលដែលលំបាកជាងគេនៅក្នុងជីវិតទេ អ៊ុំប្រុស?

ខ៖ និយាយរួមទៅជីវិតរបស់ខ្ញុំ ទោះមុខពលពតក៏ជីវិតខ្ញុំលំបាកដែរ
ហើយមកជំនាន់ពលពតនឹងក៏ពិបាក ពិបាកមួយចប់
រហូតមកដល់ឥលូវនឹងក៏នៅតែពិបាកដែរ។

ក៖ ហើយអញ្ចឹង តើអ៊ុំប្រុសធ្លាប់មានបទពិសោធន៍ល្អៗទេ ដូចជា រៀបការកូន បុណ្យទាន
ធ្លាប់មានទេ អ៊ុំប្រុស?

ខ៖ ខ្ញុំធ្វើបុណ្យទានអីនៅក្នុងផ្ទះ នៅក្នុងរង្វង់គ្រួសារខ្ញុំអី អត់ទាន់មានបានធ្វើទេ តែបើបុណ្យទានដែលគេបបួលខ្ញុំទៅវត្តនៅព្រៃវែង នៅកំពង់ធំអីនឹងណា កំពង់ស្ពឺអីនឹងណា ខ្ញុំចេះតែទៅជាមួយគេ។

ក៖ ហើយអញ្ចឹង ពេលដែលទៅជាមួយគេចឹង តើអ៊ុំប្រុសមានអារម្មណ៍យ៉ាងម៉េចដែរ អ៊ុំប្រុស?

ខ៖ សប្បាយណាស់ ពេលបានដើរធ្វើបុណ្យសប្បាយ។

ក៖ អូ! ពេលបានធ្វើបុណ្យសប្បាយចិត្ត។ ហើយអញ្ចឹងសំរាប់អ៊ុំប្រុស នៅពេលដែលអ៊ុំប្រុសនៅក្មេងតើអ៊ុំប្រុសធ្លាប់មានក្ដីសង្ឃឹមថា ពេលធំឡើងចង់ធ្វើអ្វីមួយទេ អ៊ុំប្រុស?

ខ៖ ចិត្តនឹងចង់រៀនសូត្រអោយចេះដឹង ប៉ុន្តែជីវិតរបស់យើងអ្នកក្រវាពិបាកណាស់ ម្ដាយអ្នកក្រ ហើយឪពុកអ្នកក្រ យើងមិនអាចឈានទៅរៀនសូត្រអោយបានចេះដឹងជ្រៅជ្រះវាអត់បាន ព្រោះជីវិតយើង ឪពុកម្ដាយយើងអ្នកខ្សត់ខ្សោយ។

ក៖ ហើយអញ្ចឹងជាចុងក្រោយនេះ បើសិន អ៊ុំប្រុសចង់ផ្ដាំផ្ញើរទៅកូនចៅជំនាន់ក្រោយ តើអ៊ុំប្រុសនឹងផ្ដាំផ្ញើរអ្វីខ្លះដែរ អ៊ុំប្រុស?

ខ៖ មានផ្ដាំផ្ញើរអីទេ គ្រាន់តែផ្ដាំផ្ញើរថា អោយកូនចៅខំរកស៊ីអីចឹងនឹង ដូចចៅៗចឹងណា ទូន្មានអោយខំរៀនសូត្រទៅអោយបានចេះដឹង សំរាប់យើងទៅអនាគតទៅមុខ អោយយើងបានធូរធារ អោយបានស្រួលខ្លួន អោយខំរៀនសូត្រទៅ។

ក៖ ហើយអញ្ចឹង បើសិនជាអ៊ុំប្រុសចង់អោយពួកគាត់ជៀសវាង តើអ៊ុំប្រុសចង់អោយគាត់ជៀសវាងពីអ្វីខ្លះដែលមិនល្អ?

ខ៖ ជៀសវាងកុំលួចឆក់ប្លន់គេ កុំកាប់សំលាប់គេ មានគ្រឿងញៀនអីជៀសអោយឆ្ងាយកុំអោយ មាន។

ក៖ អញ្ចឹងសំរាប់ខ្ញុំអរគុណច្រើនហើយអ៊ុំប្រុស ដែលបានចំណាយពេលអោយខ្ញុំបានសម្ភាសន៍អំពី ជីវប្រវត្តិរបស់អ៊ុំប្រុស អំពីការលំបាករបស់អ៊ុំ ហើយចុងក្រោយខ្ញុំសូមជូនពរអ៊ុំប្រុសមានសុខភាពល្អ ក្រុមគ្រួសារមានសុភមង្គល ហើយខ្ញុំសង្ឃឹមថាតាមរយៈការសម្ភាសន៍ដែលយើងមាននេះ នឹងជួយដល់កូនចៅអ៊ុំប្រុស ថាគាត់នឹងរៀនពីជីវិតរបស់អ៊ុំ ដើម្បីពួកគាត់មានការតស៊ូនៅក្នុងជីវិត។ ហើយ  អញ្ចឹងសំរាប់ខ្ញុំចុងក្រោយនឹង

សំរាប់ការសម្ភាសន៍ដែលយើងបានថតនឹង
យើងនឹងយកទៅដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ ប៊ី វ៉ាយ យ៉ូ
នៅសហរដ្ឋអាមេរិច ដើម្បីទុកអោយកូនចៅរបស់យើងគេអាចចូលទៅមើល
ហើយយើងនឹងថតរូបអ៊ុំប្រុសមួយដែរដើម្បីដាក់ភ្ជាប់ទៅជាមួយគ្នា ហើយអញ្ចឹង
តើអ៊ុំប្រុសយល់ព្រមអោយខ្ញុំយករូបថត ហើយនឹងសំលេងរបស់អ៊ុំប្រុស ដាក់នៅលើ
វេបសាយរបស់សាកលវិទ្យាល័យទេ អ៊ុំប្រុស?

ខ៖ មានអី យកទៅដាក់ទៅ។

ក៖ ហើយអញ្ចឹង អរគុណច្រើនហើយអ៊ុំប្រុស។